រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

018KH01A-01

ពិធីកាច់នំបុ័ង



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

១៨

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ព្រះយេស៊ូ និង លោកប៉ូលដែលជាសាវ័ករបស់ព្រះអង្គ បាន បង្ហាញអំពីការធ្វើពិធីកាច់នំប៉័ង ដូចខាងក្រោមនេះ ។

«ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ ។ អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច» ។ ... ព្រះយេស៊ូឈ្វេងយល់ថា ពួកសាវ័ករអ៊ូរទាំពីពាក្យទាំងនេះ ព្រះអង្គមានព្រះបន្ទូលទៅគេថា÷ *«មានតែព្រះវិញ្ញាណទេ ដែលផ្តល់ជីវិត និស្ស័យលោកីយ៍មិនអាចផ្តល់ជីវិតបានឡើយ ។ រីឯពាក្យដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណដែលផ្តល់ជីវិត »* ។

(យ៉ូហាន ៦:៥៤, ៦១, ៦៣)

«នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ។ ចូរធ្វើដូច្នេះ ដើម្បីរំលឹកដល់ខ្ញុំ » ។ ... ទ្រង់យកពែងមកកាន់ ទាំងមានព្រះបន្ទូលថា÷ *«នេះជាពែងនៃសម្ពន្ធមេត្រីថ្មី ចងឡើងដោយលោហិតរបស់ខ្ញុំ គ្រប់ពេលដែលអ្នករាល់គ្នាពិសា ចូរធ្វើដូច្នេះ ដើម្បីរំលឹកដល់ខ្ញុំ »* ។

(លូកា ២២:១៩-២០)

កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រទានពរ ក្នុងពិធីកាច់នំប៉័ង ។
- ចងចាំពីរបៀបធ្វើពិធីកាច់នំប៉័ង ។
- ជីកនាំ (ឬ ជួយជីកនាំ) ពិធីកាច់នំប៉័ងដោយទៀងទាត់ ។ (មានតែពួកអ្នកដែលក្រុមជំនុំបានតែងតាំងប៉ុណ្ណោះ ដែលគួរជីកនាំកម្មវិធីនេះ) ។
- ជីកនាំ (ឬ ជួយជីកនាំ) ពិធីកាច់នំប៉័ងឱ្យបានទៀងទាត់ ។
- បង្រៀនក្រុមជំនុំ ឬ ក្រុមរបស់អ្នកអំពីពិធីកាច់នំប៉័ង :
  - ពេលដែលត្រូវធ្វើពិធីកាច់នំប៉័ង ។
  - មូលហេតុដែលយើងត្រូវធ្វើពិធីកាច់នំប៉័ង ។
  - អ្នកដែលត្រូវចូលរួមក្នុងពិធីកាច់នំប៉័ង ។
  - របៀបកែតម្រង់សមាជិក ដែលពិបាកគ្រប់គ្រង (អ្នកដែលមិនគួរចូលរួម) ។

«ពែងនៃព្រះពរ... យើងចូលរួមជាមួយព្រះលោហិតរបស់ព្រះគ្រីស្ត ។ នំប៉័ង... យើងចូលរួមជាមួយព្រះកាយរបស់ព្រះគ្រីស្តដែរ» ។

(១ កូរិនថូស ១០:១៦)

«ហេតុនេះ ប្រសិនបើអ្នកណាពិសានំប៉័ង និង ពិសាពីពែងរបស់ព្រះ-អម្ចាស់ ដោយមិនសមរម្យ អ្នកនោះនឹងមានកំហុស ដោយមិនបានគោរពព្រះកាយ និង ព្រះលោហិតរបស់ព្រះអម្ចាស់ ។ ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិន សឹមពិសានំប៉័ង និងពិសាពីពែង របស់ព្រះអម្ចាស់ ។ ដ្បិតអ្នកណាពិសានំប៉័ង និង ពិសាពីពែងនោះ ដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកជាក់លើខ្លួនឯងផ្ទាល់ ។ ហេតុនេះហើយបានជានៅក្នុងចំណោមបងប្អូន មានគ្នាច្រើនខ្សោយកំឡាំង និង ឈឺ ហើយមានមួយចំនួនធំបានស្លាប់ » ។

(១ កូរិនថូស ១១:២៨-៣០)

ក្រុមជំនុំខ្លះចាត់ទុកនំបុ័ងជារូបកាយរបស់ព្រះគ្រីស្ត ។ ខ្លះទៀត បដិសេធថា ព្រះជាម្ចាស់ធ្វើការអស្ចារ្យ តាមរបៀបគ្រប់យ៉ាង ។ អ្នកខ្លះទៀតនិយាយថា ព្រះជាម្ចាស់ធ្វើការនៅក្នុងយើង មិនមែនធ្វើការអស្ចារ្យនៅក្នុងនំបុ័ង ដែលគ្មានជីវិតនោះទេ ។ ភារកិច្ចរបស់យើង គឺបញ្ជាក់អោយច្បាស់ពីព្រះបន្ទូលព្រះជាម្ចាស់អំពីការនេះ ។

រីឯខ្ញុំ ខ្ញុំបានជំរាបបងប្អូនន្វវសេចក្តីដែលខ្ញុំបានទទួលពីព្រះអម្ចាស់មកថា នៅយប់ដែលព្រះអម្ចាស់យេស៊ូ ត្រូវគេបញ្ជូនទៅឆ្កាង ព្រះអង្គយកនំបុ័ងមកកាន់ ទ្រង់អរព្រះគុណព្រះជាម្ចាស់ ហើយកាច់នំបុ័ងនោះ ទាំងមានព្រះបន្ទូលថា÷ «នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ។ ចូរធ្វើដូច្នេះ ដើម្បីរំលឹកដល់ខ្ញុំ» ។ លុះជប់លៀងរួចហើយ ព្រះអង្គធ្វើតាមបែបដដែល ទ្រង់យកពែងមកកាន់ ទាំងមានព្រះបន្ទូលថា÷ «នេះជាពែងនៃសម្ពន្ធមេត្រីថ្មីចងឡើងដោយលោហិតរបស់ខ្ញុំ គ្រប់ពេលដែលអ្នករាល់គ្នាពិសាចូរធ្វើដូច្នេះ ដើម្បីរំលឹកដល់ខ្ញុំ » ។ រៀងរាល់ពេលដែលបងប្អូនពិសានំបុ័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទីវង្គត រហូតដល់ព្រះអង្គយាងមកវិញ ។



ការជួនទឹកទំពាំងបាយជូរ :

- អរព្រះគុណព្រះជាម្ចាស់ចំពោះព្រះលោហិតរបស់ព្រះគ្រីស្ត ដែលបង្ហូរ ដើម្បីលើកលែងទោសយើងឱ្រួចពីអំពើបាប ។
- អានម៉ាថាយ ២៦:២៧-២៨ (ឬវគ្គផ្សេងទៀត ដែលស្តីអំពី "នេះជាព្រះលោហិតខ្ញុំ") ។
- ចែកទឹកទំពាំងបាយជូរ និងទុកពេលបន្តិច ដើម្បីអធិស្ឋានក្នុងចិត្ត ។

ច្រៀងក្នុងពិធី ដោយអំណរ ពីការលើកលែងទោស និង ការរួមចំណែកជាមួយព្រះអង្គ ។

© Project WorldReach © SEAN

ប្រព្រឹត្តអំពើបាប ។ ចូរយើងកុំធ្វើដូច្នេះឡើយ ។ បើធ្វេសប្រហែសមិនធ្វើពិធីកាច់នំបុ័ង នោះធ្វើអោយបងប្អូននៅក្នុងក្រុមជំនុំជំពប់ដួល និងទៅជាខ្សោយជាមិនខាន ។

នៅក្នុងក្រុមជំនុំក្រុងកូរិនថូស មានសមាជិកខ្លះបានប្រព្រឹត្តអំពើបាបគ្រប់យ៉ាង ។ សាវ័កប៉ូលយល់ព្រមអោយក្រុមជំនុំទាំងមូលធ្វើពិធីកាច់នំបុ័ង ។ ប៉ុន្តែ លោកបង្គាប់ដល់អ្នក ដែលនៅតែប្រព្រឹត្តបាបនោះ មិនឱ្យចូលរួមក្នុងពិធីកាច់នំបុ័ងទេ (១ កូរិនថូស ៥)។

របៀបធ្វើពិធីកាច់នំបុ័ង

(សូមប្រើរបៀបនេះ ប្រសិនបើក្រុមជំនុំរបស់អ្នកមិនទាន់មានរបៀបធ្វើពិធីនេះច្បាស់លាស់) ។

អធិស្ឋានក្នុងចិត្ត និងលន់តួសារភាពអំពើបាបរបស់ខ្លួន ។

ការថ្វាយនំបុ័ង :

- អរព្រះគុណចំពោះព្រះកាយរបស់ព្រះគ្រីស្តសំរាប់យើង ។
- អានម៉ាថាយ ២៦:២៦ (ឬវគ្គផ្សេងៗទៀត ដែលស្តីអំពី "នេះជារូបកាយខ្ញុំ") ។
- ចែកនំបុ័ង និងទុកពេលបន្តិច ដើម្បីអធិស្ឋានក្នុងចិត្ត ។

ហេតុនេះ ប្រសិនបើអ្នកណាពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ ដោយមិនសមរម្យ អ្នកនោះនឹងមានកំហុស ដោយមិនបានគោរពព្រះកាយ និងព្រះលោហិតរបស់ព្រះអម្ចាស់ ។ ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិនសឹមពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ ។ ដ្បិតអ្នកណាពិសានំបុ័ង និងពិសាពីពែងនោះ ដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់ ។ ហេតុនេះហើយបានជានៅក្នុងចំណោមបងប្អូនមានគ្នាច្រើនខ្សោយកំឡាំង និងឈឺ ហើយមានមួយចំនួនធំបានស្លាប់ ។ ប្រសិនបើយើងពិនិត្យពិច័យមើលខ្លួនឯង ព្រះអម្ចាស់នឹងមិនវិនិច្ឆ័យទោសយើងទេ ប៉ុន្តែ បើព្រះអម្ចាស់វិនិច្ឆ័យទោសយើង មកពីព្រះអង្គចង់កែយើង ដើម្បីកុំអោយយើងទទួលទោសជាមួយលោកីយ៍ ។

ហេតុនេះ បងប្អូនអើយ នៅពេលបងប្អូនជួបជុំគ្នាបរិភោគពិធីជប់លៀងរបស់ព្រះអម្ចាស់ ត្រូវចាំគ្នាផង ។ ប្រសិនបើអ្នកណាឃ្លាន អ្នកនោះត្រូវពិសាបាយពីផ្ទះអោយហើយទៅ ដើម្បីចៀសវាងកុំអោយការប្រជុំរបស់បងប្អូន ទៅជាមានទោសទៅវិញ ។

(១ កូរិនថូស ១១:២៣-៣៤)

ក្រោយពីបានអាន ១ កូរិនថូស ១១:២៣-៣៤ រួចហើយ សូមឆ្លើយសំណួរជាបន្តបន្ទាប់នេះ ។

តើនរណាជាអ្នកតែងតាំងអោយមានពិធីកាច់នំបុ័ងឡើង ?

_____

តើនំបុ័ងតំណាងអ្វី ?

_____

តើទឹកទំពាំងបាយជូរតំណាងអ្វី ? _____

តើយើងធ្វើពិធីកាច់នំបុ័ង ដើម្បីរំលឹកពីនរណា ? _____

រាល់ពេលដែលយើងបរិភោគនំបុ័ង និងពិសាទឹកទំពាំងបាយជូរ តើយើងប្រកាសអំពីអ្វី ?

_____

_____

តើមានគ្រោះថ្នាក់អ្វីអាចនឹងកើតឡើង ប្រសិនបើយើងចូលរួមធ្វើពិធីកាច់នំបុ័ងតាមបែបមិនសមរម្យ ?

_____

ព្រះអម្ចាស់យេស៊ូប្រទានជំហានបីដល់យើង :

១- និយាយជាមួយអ្នកនោះ ដោយស្ងាត់ៗ (ម៉ាថាយ ១៨:១៥) ហើយមិនត្រូវរិះគន់អ្នកនោះឡើយ (ម៉ាថាយ ៧:១) ។

២- បើគេមិនព្រមស្តាប់អ្នកទេ សូមនាំសាក្សីពីរ ឬបីនាក់អោយនិយាយជាមួយគេ ហើយក្រើនរំលឹកគេ ។ និយាយជាមួយគេ ដោយចិត្តស្លូតបូត (ម៉ាថាយ ១៨:១៦, កាឡាទី ៦:១, ១ ធីម៉ូថេ ៥:១៩) ។

៣- បើគាត់នៅតែមិនព្រមស្តាប់ពួកគេទៀត ត្រូវនាំរឿងនេះទៅប្រាប់ក្រុមជំនុំអោយជួយដោះស្រាយ ហើយបើគាត់នៅតែមិនព្រមកែប្រែចិត្តគំនិតទៀត មិនត្រូវរាប់បញ្ចូលគាត់ក្នុងក្រុមជំនុំទៀតឡើយ រហូតដល់គាត់កែប្រែចិត្តគំនិត និងប្រតិបត្តិតាមបង្គាប់របស់ព្រះជាម្ចាស់វិញ (ម៉ាថាយ ១៨:១៧-១៨, ១ កូរិនថូស ៥:៤-១១) ។

ពិធីកាច់នំបុ័ង គឺជាទីសំគាល់ពីការចូលរួមចំណែករបស់យើងជាមួយព្រះអម្ចាស់ និងគ្រីស្តជនឯទៀត ។ យើងមិនត្រូវអោយអ្នកដែលមិនចង់ចូលរួម ទទួលពិធីនេះទេ ។ គ្រួគង្វាលខ្លះ មិនធ្វើពិធីកាច់នំបុ័ងក្នុងក្រុមជំនុំទេ ដោយសារតែមានសមាជិកម្នាក់បាន

ក្រុមជំនុំនៅទីក្រុងកូរិនថូស ដែលចូលរួមដោយមិនអោយតំលៃ ទៅលើពីធីកាច់នំប៉័ង បានទទួលទោសពីព្រះជាម្ចាស់ (១ កូរិន-ថូស ១១:២៩-៣០) ។

នៅពេលដែលគ្រីស្តជនណាម្នាក់ ដែលមិនចេះស្តាប់បង្គាប់ បានកែប្រែចិត្តគំនិត និងត្រូវបានសម្រុះសម្រួលអោយជានាជាមួយព្រះជាម្ចាស់ និងក្រុមជំនុំហើយ ភ្លាមនោះ គាត់ត្រូវចាប់ផ្តើមចូលរួមធ្វើពិធីកាច់នំប៉័ងវិញ ។ ពិធីកាច់នំប៉័ង បញ្ជាក់ពីព្រះហឫទ័យប្រណីសន្តោសដ៏ធំធេងរបស់ព្រះជាម្ចាស់ និងបញ្ជាក់ថាព្រះអង្គលើកលែងទោសអ្នកចូលរួមអោយរួចពីបាប ។ ពិធីកាច់នំប៉័ងតំណាងសម្ពន្ធមេត្រីថ្មី (លូកា ២២:២០) ។ កាតព្វកិច្ចរបស់យើងតាមសម្ពន្ធមេត្រីថ្មី គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក (រ៉ូម ១៣:៨:១០) ។

តើយើងត្រូវកែតម្រង់ពួកអ្នកដែលកំពុងប្រព្រឹត្តអំពើបាប ដោយរបៀបណា ?

បើយើងដឹងពិតប្រាកដថា មានគ្រីស្តជនម្នាក់នៅតែប្រព្រឹត្តអំពើបាប យើងត្រូវព្យាយាមកែតម្រង់គេ ។ គឺថាមិនមែនថ្កោលទោសគេទេ តែត្រូវកែតម្រូវគេ ដោយសេចក្តីស្រឡាញ់វិញ (កាឡាទី ៦:១) ។

ហេតុអ្វីបានជាយើងត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់យើងជាមុនសិន ?

តើយើងធ្វើពិធីកាច់នំប៉័ង នៅពេលណា ?

ក្រុមជំនុំដែលធ្វើពិធីកាច់នំប៉័ងដោយទៀងទាត់ តែងតែបានទទួលព្រះពរពីព្រះអម្ចាស់ ដោយសារតែពួកគេចេះស្តាប់បង្គាប់ ។ ក្រុមជំនុំណាដែលធ្វេសប្រហែស មិនធ្វើតាមបទបញ្ជានេះ គឺជាក្រុមជំនុំ ដែលមិនប្រតិបត្តិតាមសេចក្តីបង្គាប់ និងមិនលើកសិរីរុងរឿងរបស់ព្រះអម្ចាស់យេស៊ូ ហើយក្រុមជំនុំនោះនឹងមានបញ្ហាជាមិនខាន ។

នៅក្នុងក្រុមជំនុំរបស់ពួកសាវ័ក គេចូលរួមធ្វើពិធីកាច់នំប៉័ងរៀងរាល់អាទិត្យ (កិច្ចការ ២០:៧) ។ ទោះជាព្រះអម្ចាស់យេស៊ូមិនបានបញ្ជាក់អោយយើងធ្វើរាល់អាទិត្យក៏ដោយ ក៏ការធ្វើពិធីនេះដោយទៀងទាត់ មានសារៈប្រយោជន៍ដល់ការអធិស្ឋាន និងការទូន្មានអប់រំរបស់ក្រុមជំនុំដែរ ។ សូមកុំគិតថា ដើម្បីធ្វើពិធីកាច់នំប៉័ង អ្នកត្រូវតែមានក្រុមជំនុំ ដែលមានគ្នាច្រើននោះឡើយ ។

ព្រោះពេលមានមនុស្សពីរ ឬ បីនាក់ជួបជុំគ្នាក្នុងព្រះនាមព្រះអង្គ ព្រះអង្គក៏មានវត្តមាននៅក្នុងចំណោមពួកគេផងដែរ ។

តើក្រុមជំនុំរបស់អ្នកធ្វើពិធីកាច់នំបុ័ង នៅពេលណា ?_____

កំណត់ចំណាំ : ក្រុមជំនុំផ្សេងៗមានរបៀបធ្វើពិធីនេះផ្សេងៗពីគ្នា ។ សូមយកសេចក្តីបង្រៀននេះ ទៅអនុវត្តតាមលទ្ធភាព និងតាមស្ថានភាពរបស់ខ្លួនអ្នកផ្ទាល់ ។

ហេតុអ្វីបានជាយើងធ្វើពិធីកាច់នំបុ័ង ?

កំណត់សំគាល់ :

ក) ក្រុមជំនុំខ្លះហៅពិធីកាច់នំបុ័ងជា "ពិធីរួមចិត្តគ្នា" "ពិធីជប់លៀងរបស់ព្រះអម្ចាស់" ឬ ក៏ "ពិធីអរព្រះគុណ" ។

ខ) ពួកសាវ័កបានប្រើ"ស្រា"តែក្រុមជំនុំខ្លះនិយមប្រើទឹកទំពាំងបាយជូរ ឬភេសជ្ជៈផ្សេងៗ គ្មានជាតិស្រវឹង ដែលមាននៅតាមតំបន់របស់គេ ។

តើអ្នកណាខ្លះ ដែលគួរចូលរួមក្នុងពិធីកាច់នំបុ័ង ?

ពិធីកាច់នំបុ័ង គឺសំរាប់តែអ្នកជឿលើព្រះអម្ចាស់យេស៊ូគ្រីស្ត ប៉ុណ្ណោះ ។



«ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិនសឹមពិសានំបុ័ង និង ពិសាពីពែងរបស់ព្រះអម្ចាស់ » ។

(១ កូរិនថូស ១១:២៨)

© Project WorldReach © SEAN

ពិធីកាច់នំបុ័ងជាទីសំគាល់អំពីសម្ពន្ធមេត្រីថ្មី ដែលព្រះជាម្ចាស់ចងឡើងជាមួយយើង តាមរយៈព្រះលោហិតរបស់ព្រះបុត្រាទ្រង់ គឺព្រះយេស៊ូគ្រីស្ត ។ ព្រះអម្ចាស់មានព្រះបន្ទូលនៅក្នុងគម្ពីរម៉ាថាយ ២៦:២៨ ថា÷

«នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រី ដែលត្រូវបង្ហូរដើម្បីលើកលែងទោសមនុស្សទាំងអស់អោយរួចពីបាប » ។



សូមពន្យល់អំពីពិធីកាច់នំបុ័ង ជាមុន នៅពេលជួបជុំគ្នាមួយផ្សេង គឺយើងមិនចាំបាច់ធ្វើការពន្យល់វែងឆាយពេលធ្វើពិធីកាច់នំបុ័ងនោះទេ ។ នំបុ័ង និងទឹកទំពាំងបាយជូរជួយអោយអ្នកដែលចូលរួម នឹកចាំអំពីអត្ថន័យនៃពិធីកាច់នំបុ័ងនេះហើយ ។



យើងនឹងចូលរួមធ្វើពិធីកាច់នំបុ័ង ដោយយកចិត្តទុកដាក់ ។ ខ្ញុំចង់អោយសមាជិករបស់ខ្ញុំរីកចំរើនឡើងរឹងមាំ និងចងចាំពីពលិកម្មដ៏ធំរបស់ព្រះអង្គនៅលើឈើឆ្កាងតែមួយដង សំរាប់មនុស្សទាំងអស់ ។



- យើងរំពឹងគិតយ៉ាងខ្លាំងអំពីការបូជាជីវិត ការមានព្រះជន្ម រស់ឡើងវិញ ប្រកបដោយសិរីរុងរឿង និងការយាងមកជាលើកទីពីររបស់ព្រះអង្គ ។
- ពិធីកាច់នំប៉័ងបញ្ជាក់ និងធ្វើអោយឯកភាព និងសេចក្តីស្រឡាញ់របស់ក្រុមជំនុំមានបន្តជាថ្មី ។ *«មាននំប៉័ងតែមួយប៉ុណ្ណោះ ទោះបីយើងមានគ្នាច្រើនក្តី ក៏យើងរួមគ្នាមកជារូបកាយតែមួយដែរ ។ ព្រោះយើងទាំងអស់គ្នាបានទទួលចំណែកពីនំប៉័ងតែមួយ »* (១ កូរិនថូស ១០:១៧) ។
- ពិធីកាច់នំប៉័ងសំខាន់ខ្លាំងណាស់ ។ ក្រុមជំនុំទាំងអស់ត្រូវចាត់តាំងអ្នកជួយបំរើក្នុងពិធីនេះ អោយបានសមរម្យ ដើម្បីអោយពួកគេបំរើពិធីនេះ តាមរបៀបរៀបរយ ។

ឬ ? ចុះបើអ្នករាល់គ្នាឃើញបុត្រមនុស្សឡើងទៅស្ថានដែលលោកនៅពីមុនវិញ តើចិត្តអ្នករាល់គ្នានឹងទៅជាយ៉ាងណា ? មានតែព្រះវិញ្ញាណទេ ដែលផ្តល់ជីវិត និស្ស័យលោកីយ៍មិនអាចផ្តល់ជីវិតបានឡើយ ។ រីឯពាក្យដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណ ដែលផ្តល់ជីវិត » ។

- ព្រះជាម្ចាស់អោយយើងចូលរួមក្នុងព្រះកាយរបស់ព្រះគ្រីស្ត ដោយហ្មត់ចត់ត្រឹមត្រូវណាស់ ។ ព្រះអង្គព្រមានយើងនៅក្នុង ១ កូរិនថូស ១១:២៨-៣០ ថា÷ *«ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិន សឹមពិសានំបុ័ង និង ពិសាពីពែងរបស់ព្រះអម្ចាស់ ។ ដ្បិតអ្នកណាពិសានំបុ័ង និង ពិសាពីពែងនោះ ដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់ ។ ហេតុនេះហើយបានជានៅក្នុងចំណោមបងប្អូន មានគ្នាច្រើនខ្សោយកំឡាំង និង ឈឺ ហើយមានមួយចំនួនធំបានស្លាប់ »* ។

នេះជាសេចក្តីសន្យា :

អស់អ្នកដែលជឿលើព្រះអម្ចាស់យេស៊ូគ្រីស្ត នឹងទទួលការលើកលែងទោសឱ្យរួចពីបាប ហើយនិងទទួលជីវិតថ្មី ជីវិតបរិសុទ្ធ និងជីវិតអស់កល្ប ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ (កិច្ចការ ២:៣៨, កាឡាទី ៣:១៤, ហេប្រឺ ៨:១០, ហេប្រឺ ៩:១៥) ។

ពេលដែលយើងចូលរួមធ្វើពិធីកាច់នំបុ័ង គឺ :

- យើងធ្វើអោយជំនឿ និងការប្តេជ្ញាចិត្តរបស់យើងចំពោះព្រះអម្ចាស់យេស៊ូគ្រីស្ត មានបន្តជាថ្មី ។
- នៅក្នុងលូកា ២២:១៩-២០ នៅពេលដែលព្រះអម្ចាស់-យេស៊ូយកនំបុ័ងមកកាច់ ព្រះអង្គបានបង្គាប់ថា÷ *«នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ។ ចូរធ្វើដូច្នេះដើម្បីរំលឹកដល់ខ្ញុំ »* ។ ...ទ្រង់យកពែងមកកាន់ទាំងមានព្រះបន្ទូលថា÷ *«នេះជាពែងនៃ សម្ពន្ធមេត្រីថ្មីចងឡើងដោយសារលោហិតរបស់ខ្ញុំ ដែលត្រូវបង្ហូរសំរាប់អ្នករាល់គ្នា »* ។ ក្រុមជំនុំមានទស្សនៈប្លែកៗពីគ្នា ស្តីអំពីពិធីកាច់នំបុ័ង ។ អ្នកខ្លះនិយាយថា ព្រះជាម្ចាស់បំផ្លាស់បំប្រែនំបុ័ងអោយក្លាយជារូបកាយរបស់ព្រះគ្រីស្ត ។ ខ្លះទៀតបដិសេធ

អំពីការនេះ តែគេថាព្រះជាម្ចាស់ធ្វើការអស្ចារ្យតាមរបៀបផ្សេងមួយទៀត ។ អ្នកខ្លះទៀត និយាយថា ព្រះជាម្ចាស់ធ្វើការនៅក្នុងយើង (មិនមែនធ្វើការអស្ចារ្យ នៅក្នុងនំបុ័ងដែលគ្មានជីវិតនោះទេ) គឺដើម្បីអោយជីវិតរបស់ព្រះអង្គរួមចំណែកជាមួយនឹងយើង ។ យើងមិនមែនជំទាស់នឹងទស្សនៈណាមួយនោះទេ ប៉ុន្តែ យើងត្រូវដឹងពីសេចក្តីចែងនៅក្នុងបទគម្ពីរ ។ ព្រះគ្រីស្តមិនមែននិយាយថា នេះជាការរំលឹកទេ ប៉ុន្តែ ព្រះអង្គមានព្រះបន្ទូលថា «*សូមធ្វើកិច្ចការនេះ* » ដើម្បីរំលឹកអំពីព្រះអង្គ ។ ការសំខាន់ គឺការចូលរួមជាមួយព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ ដូចលោកប៉ូលបានមានប្រសាសន៍នៅក្នុង ១ កូរិនថូស ១០:១៦ ថា÷ «*ពេលយើងលើកពែងនៃព្រះពរឡើង ដើម្បីអរព្រះគុណព្រះជាម្ចាស់ មានន័យថា យើងចូលរួមជាមួយព្រះលោហិតរបស់ព្រះគ្រីស្ត រីឯពេលដែលយើងកាច់នំបុ័ងក៏មានន័យថា យើងចូលរួមជាមួយព្រះកាយរបស់ព្រះគ្រីស្តដែរ* » ។

- នៅក្នុងបទគម្ពីរយ៉ូហាន ៦:៥៣-៦៣ : ព្រះគ្រីស្តបានមានព្រះបន្ទូលជាស់ស្មារតីយើង អោយចូលរួមក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គថា÷ «*...ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នា គ្មានជីវិតក្នុងខ្លួនឡើយ ។ អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំនឹងប្រោសឱ្យគេមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង ។ សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ ។ អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ ។ ព្រះបិតាដែលបានចាត់ខ្ញុំអោយមកទ្រង់មានព្រះជន្មរស់ ហើយខ្ញុំមានជីវិត ដោយសារព្រះអង្គយ៉ាងណា អ្នកបរិភោគសាច់ខ្ញុំ ក៏នឹងមានជីវិតរស់ដោយសារខ្ញុំ យ៉ាងនោះដែរ* »។...*ព្រះយេស៊ូឈ្វេងយល់ថា ពួកសាវ័ករអ៊ូរទាំពីពាក្យទាំងនេះ ព្រះអង្គមានព្រះបន្ទូលទៅគេថា÷ «តើពាក្យទាំងនេះ នាំអោយអ្នករាល់គ្នារវាតចិត្ត បាត់ជំនឿ*